SECU SRM
Social & Environmental Compliance Unit
Stakeholder Response Mechanism

# តើអ្នកព្រួយបារម្ភអំពីគម្រោងរបស់ យូ.អិន.ឌី.ភី ឬ?

## ការត្រួតពិនិត្យអនុលោមភាពសង្គម និងបរិស្ថាន និង យន្តការឆ្លើយតបដល់ភាគីពាក់ព័ន្ធ

UNDP
Empowered lives.
Resilient nations.

## *សេចក្តីផ្តើម*

ប្រសិនអ្នកយល់ថាគម្រោង ឬកម្មវិធីដែលគាំទ្រដោយ **យូ.អិន.ឌី.ភី** បានបង្កគ្រោះថ្នាក់ ឬអាចនឹងបង្កគ្រោះថ្នាក់ ដល់អ្នក, ដល់សហគមន៍របស់អ្នក, ឬដល់បរិស្ថាន, អ្នកអាចស្នើសុំជំនួយពី "អង្គភាពអនុលោមភាពសង្គម និងបរិស្ថានរបស់ **យូ.អិន.ឌី.ភី**" និង/ឬ "យន្តការឆ្លើយតបដល់ភាគីពាក់ព័ន្ធរបស់ **យូ.អិន.ឌី.ភី**"។

## ***ការត្រួតពិនិត្យអនុលោមភាព៖*** *ឆ្លើយតបទៅនឹងកង្វល់ពាក់ព័ន្ធនឹងការប្តេជ្ញារបស់ យូ.អិន.ឌី.ភី ផ្នែកសង្គម និងបរិស្ថាន*

"អង្គភាពអនុលោមភាពសង្គម និងបរិស្ថាន (**អេស.អ៊ី.ស៊ី.យូ**)" ស៊ើបអង្កេតលើការតវ៉ារបស់សហគមន៍ និងឯកត្តបុគ្គលទទួលរងការប៉ះពាល់ពីគម្រោង ដែលយល់ថា **យូ.អិន.ឌី.ភី** មិនអនុលោមតាមការប្តេជ្ញារបស់ខ្លួនពាក់ព័ន្ធនឹងសង្គម និងបរិស្ថាន ហើយផ្តល់យោបល់អំពីវិធានការដើម្បីដោះស្រាយករណីដែលរកឃើញថាមិនអនុលោម។ ជាក់ស្តែង ករណីនេះរួមបញ្ចូល ការមិនអនុលោមតាមស្តង់ដាផ្នែកសង្គម និងបរិស្ថានរបស់ **យូ.អិន.ឌី.ភី**។

## ***ការឆ្លើយតបដល់ភាគីពាក់ព័ន្ធ៖*** *ជួយភាគីពាក់ព័ន្ធដោះស្រាយវិវាទ និងសេចក្តីទុក្ខព្រួយ*

"យន្តការឆ្លើយតបដល់ភាគីពាក់ព័ន្ធ (**អេស.អ.អឹម**)" ជួយភាគីពាក់ព័ន្ធ, ដៃគូរបស់ **យូ.អិន.ឌី.ភី** (រដ្ឋាភិបាល, អង្គការក្រៅរដ្ឋាភិបាល, ក្រុមហ៊ុនអាជីវកម្ម) និងភាគីផ្សេងទៀតដែលទទួលរងការប៉ះពាល់ពីគម្រោង ដើម្បីរួមគ្នាដោះស្រាយវិវាទ ឬសេចក្តីទុក្ខព្រួយ អំពីផលប៉ះពាល់លើសង្គម និង/ឬ បរិស្ថាន របស់គម្រោងដែលគាំទ្រដោយ **យូ.អិន.ឌី.ភី**។

## *តើនរណាអាចដាក់ពាក្យតវ៉ាបាន?*

បុគ្គល ឬសហគមន៍ណាក៏ដោយ ដែលយល់ឃើញថាបរិស្ថាន ឬសុខុមាលភាពរបស់ពួកគេអាចរងផលប៉ះពាល់ ដោយសារគម្រោង ឬកម្មវិធីដែលគាំទ្រដោយ **យូ.អិន.ឌី.ភី** អាចដាក់ពាក្យតវ៉ាបាន។ អ្នកតំណាង ដូចជាអង្គការសង្គមស៊ីវិល ក៏អាចដាក់ពាក្យតវ៉ាជំនួសសហគមន៍ដែលទទួលរងផលប៉ះពាល់បានដែរ។ អ្នកដាក់ពាក្យតវ៉ា អាចស្នើសុំឲ្យ "**អេស.អ.អឹម**" និង "**អេស.អ៊ី.ស៊ី.យូ**" ការពារអត្តសញ្ញាណ និងឈ្មោះ របស់ពួកគេ។

## *តើដាក់សំណូមពរនៅឯណា?*

សូមផ្ញើសំណូមពរ និងសំណួរផ្សេងៗមកកាន់ **អេស.អ៊ី.ស៊ី.យូ** តាមរយៈ: secuhotline@undp.org.

ការផ្ញើសំណូមពរមកកាន់ **អេស.អ.អឹម** អាចធ្វើឡើងតាមរយៈការិយាល័យ **យូ.អិន.ឌី.ភី** ប្រចាំប្រទេស នៅក្នុងប្រទេសដែលអ្នកដាក់សំណូមពររស់នៅ, ឬផ្ញើមកការិយាល័យកណ្តាលរបស់ក្រុមការងារ **អេស.អ.អឹម** តាមរយៈ: stakeholder.response@undp.org.

ព័ត៌មានទំនាក់ទំនងរបស់ការិយាល័យ **យូ.អិន.ឌី.ភី** ប្រចាំប្រទេស អាចរកមើលបាននៅក្នុងគេហទំព័ររបស់ **យូ.អិន.ឌី.ភី** www.undp.org.

## *តើត្រូវមានព័ត៌មានអ្វីខ្លះនៅក្នុងសំណូមពរ?*

ដើម្បីងាយស្រួលក្នុងការឆ្លើយតប សំណូមពររបស់អ្នក ត្រូវមានព័ត៌មានដូចខាងក្រោម៖

- ឈ្មោះ, អសយដ្ឋាន, លេខទូរស័ព្ទ និងព័ត៌មានទំនាក់ទំនងផ្សេងទៀត
- ការបញ្ជាក់ថាតើអ្នកដាក់សំណូមពរចង់រក្សាអត្តសញ្ញាណរបស់ខ្លួនជាការសម្ងាត់នៅក្នុងអំឡុងពេលនៃការវាយតម្លៃដំបូងឬក៏អត់។
- ឈ្មោះ, ទីតាំង, ប្រភេទនៃគម្រោងរបស់ **យូ.អិន.ឌី.ភី**
- ការបញ្ជាក់ថាតើអ្នកដាក់សំណូមពរ បានទទួលរងគ្រោះ ឬអាចនឹងទទួលរងគ្រោះពីគម្រោងដែលគាំទ្រដោយ **យូ.អិន.ឌី.ភី** ដោយរបៀបណា។
- ការពិពណ៌នាអំពីការខិតខំផ្សេងៗ រួមមានដំណើរការនៃការដោះស្រាយវិវាទ ដែលអ្នកដាក់សំណូមពរបានអនុវត្តកន្លងមកក្នុងការដោះស្រាយកង្វល់របស់ពួកគេ

## *សម្រាប់ព័ត៌មានបន្ថែម*

www.undp.org/secu-srm
www.undp.org/ses
project.concerns@undp.org